ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 23-Dec-2015, 14:38
CMS/CFO: Sann Rada

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour supreme

សំណុំរឿងលេខ: ០០២/១៩-កញ្ញា-២០០៧/អ.វ.ត.ក/អ.ជ.ត.ក
Case File/Dossier N°. 002/19-09-2007/ECCC/SC

នៅចំពោះមុខ៖

ចៅក្រម គង់ ស្រ៊ឹម ប្រធាន
ចៅក្រម Chandra Nihal JAYASINGHE
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម Agniezska KLONOWIECKAMILART
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម Florence Ndepele Mwachande MUMBA
ចៅក្រម យ៉ា ណារិន

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១៥
ភាសាដើម៖ ខ្មែរ/អង់គ្លេស
ចំណាត់ថ្នាក់ឯកសារ៖ សាធារណៈ:

# ដីកាកំណត់កាលបរិច្ឆេទបន្តសវនាការលើបណ្តឹងសាទុក្ខ

**<u>សហព្រះរាជអាជ្ញា</u>**
ជា លាង
Nicholas KOUMJIAN

**<u>សហមេធាវីជនជាប់ចោទ នួន ជា</u>**
សុន អរុណ
Victor KOPPE

**<u>ជនជាប់ចោទ</u>**

ខៀវ សំផន

នួន ជា

**<u>សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>**

ពេជ អង្គ

Marie GUIRAUD

**<u>សហមេធាវីជនជាប់ចោទ ខៀវ សំផន</u>**

គង់ សំអុន

Anta GUISSÉ

Arthur VERCKEN

**អង្គជំនុំជម្រះតុលាការកំពូល**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យនៅចន្លោះពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ ("**អង្គជំនុំជម្រះតុលាការកំពូល**" និង"**អ.វ.ត.ក**" នីមួយៗ);

**រំលឹក**ថា អង្គជំនុំជម្រះតុលាការកំពូល បានចេញដីកាកំណត់កាលបរិច្ឆេទនៃសវនាការលើបណ្តឹងសាទុក្ខ ក្នុងសំណុំរឿងលេខៈ ០០២/១៩-កញ្ញា-២០០៧/អ.វ.ត.ក/អ.ជ.ត.ក កាលពីថ្ងៃទី ១៧ ដល់ ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ("សវនាការលើបណ្តឹងសាទុក្ខ")[1] ដែលត្រូវបានផ្អាករហូតទាល់តែមានការជូនដំណឹងបន្ថែម។ ការផ្អាកនេះ គឺដោយសារកង្វះការការពារក្តីស្របច្បាប់សមស្របសម្រាប់ នួន ជា ដែលបណ្តាលមកពីសហមេធាវីការពារក្តីអន្តរជាតិ ពុំបានចូលរួមសវនាការលើបណ្តឹងសាទុក្ខ ហើយសហមេធាវីជាតិបានចាកចេញពីបន្ទប់ សវនាការ បើទោះបីជាមានការបង្គាប់របស់អង្គជំនុំជម្រះតុលាការកំពូលឱ្យបន្តមានវត្តមានក៏ដោយ[2],

**កត់សម្គាល់ឃើញ**ថា អង្គជំនុំជម្រះតុលាការកំពូល បានណែនាំអង្គភាពគាំពារការការពារក្តីឱ្យចាត់តាំងមេធាវីត្រៀមបម្រុងសម្រាប់ នួន ជា[3] ដែលអង្គភាពនេះបានធ្វើឡើងកាលពីថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ ដោយបានជ្រើសតាំងមេធាវី ផាត់ ពៅស៊ាង សម្រាប់រយៈពេលបីខែដំបូង ("សហមេធាវីការពារក្តីត្រៀមបម្រុងសម្រាប់ នួន ជា")[4],

---

[1] ដីកាកំណត់កាលវិភាគស្តាពរសម្រាប់សវនាការលើបណ្តឹងសាទុក្ខ និងជូនដំណឹងភាគីអំពីបញ្ហាដែលត្រូវដោះស្រាយ, ដីកាចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឯកសារលេខ F30/4។

[2] ប្រតិចារឹកចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឯកសារលេខ F1/4.1 ទំព័រ ២, ១៤, ២៦, ៣០ ដល់ ៣១។

[3] ប្រតិចារឹកចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឯកសារលេខ F1/4.1 ទំព័រ ៣១, ព័ត៌មានពិស្តារមាននៅក្នុងអនុស្សរណៈរបស់អង្គជំនុំជម្រះតុលាការកំពូលចំណងជើងថា "ការអនុវត្តន៍តាមការណែនាំរបស់អង្គជំនុំជម្រះតុលាការកំពូលឱ្យចាត់តាំងមេធាវីត្រៀមបម្រុងសម្រាប់ នួន ជា" ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឯកសារលេខ F30/15 ("អនុស្សរណៈស្តីពីការអនុវត្តន៍តាម")។ *សូមមើលផងដែរ* អនុស្សរណៈរបស់អង្គជំនុំជម្រះតុលាការកំពូលចំណងជើងថា "ការឆ្លើយតបទៅនឹងអនុស្សរណៈរបស់អង្គភាពគាំពារការការពារក្តីចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១៥" ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឯកសារលេខ F30/15/1/1។ អនុស្សរណៈរបស់អង្គភាពគាំពារការការពារក្តីចំណងជើងថា "ការធ្វើបច្ចុប្បន្នភាពលើកទីមួយស្តីពីការណែនាំរបស់អង្គជំនុំជម្រះតុលាការកំពូលឱ្យចាត់តាំងមេធាវីត្រៀមបម្រុងសម្រាប់ នួន ជា" ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១៥ (ដាក់នៅថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៥) ឯកសារលេខ F30/15/1 (សម្ងាត់)។

[4] អនុស្សរណៈរបស់អង្គភាពគាំពារការការពារក្តីចំណងជើងថា "ការធ្វើបច្ចុប្បភាពលើកទីពីរស្តីពីការណែនាំរបស់អង្គជំនុំជម្រះតុលាការកំពូលឱ្យចាត់តាំងមេធាវីត្រៀមបម្រុងសម្រាប់ នួន ជា" ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារលេខ F30/15/2 កថាខណ្ឌ ៤។

**រំលឹក**ថា (១) តួនាទីរបស់សហមេធាវីត្រៀមបម្រុងសម្រាប់ នួន ជា ពុំមែនមកជំនួសតួនាទីរបស់សហមេធាវីការពារក្តី នួន ជា ដែលត្រូវបានជ្រើសតាំងរួចហើយនោះទេ ប៉ុន្តែគ្រាន់តែជាតួនាទីសម្រាប់ផ្តល់ជំនួយផ្នែកច្បាប់សមស្របដល់ នួន ជា ក្នុងអំឡុងពេលសវនាការ ក្នុងករណីដែលសហមេធាវីដែលត្រូវបានជ្រើសតាំងនេះ ខកខានមានវត្តមានក្នុងបន្ទប់សវនាការ នៅពេលដែលសវនាការបន្ត ឬចាកចេញពីបន្ទប់សវនាការនៅក្នុងអំឡុងពេលសវនាការលើបណ្តឹងសាទុក្ខ (២) សហមេធាវីត្រៀមបម្រុងសម្រាប់ នួន ជា ត្រូវតែចូលរួមរាល់សវនាការនៃបណ្តឹងសាទុក្ខទាំងអស់ក្នុងសំណុំរឿង ០០២/០១ និងត្រូវតែឯករាជ្យពីក្រុមមេធាវីការពារក្តី នួន ជា បច្ចុប្បន្ន និងពុំត្រូវពិគ្រោះពិភាក្សាជាមួយ ឬទទួលការណែនាំពី នួន ជា លើកលែងតែ មានការបង្គាប់ពីអង្គជំនុំជម្រះតុលាការកំពូល (៣) សហមេធាវីត្រៀមបម្រុងសម្រាប់ នួន ជា បន្ទាប់ពីមានការស្នើសុំសមហេតុផល នឹងត្រូវទទួលបានពេលវេលាគ្រប់គ្រាន់ក្នុងការស្វែងយល់ដោយខ្លួនឯងទៅលើសំណុំរឿងនេះ និង(៤) សហមេធាវីត្រៀមបម្រុងសម្រាប់ នួន ជា ពុំត្រូវបានផ្តល់សិទ្ធិឱ្យការពារក្តី នួន ជា ឡើយ ដរាបណាមានការណែនាំពីអង្គជំនុំជម្រះនេះឱ្យទទួលយកការការពារក្តីនេះ[5];

**ពិចារណាឃើញ**ថា សវនាការលើបណ្តឹងសាទុក្ខ ពុំអាចបន្តភ្លាមៗបានឡើយ ដោយសារតម្រូវការចាំបាច់ក្នុងការធានាឱ្យបានថា សហមេធាវីត្រៀមបម្រុងសម្រាប់ នួន ជា ត្រូវមានពេលវេលាគ្រប់គ្រាន់ក្នុងការសិក្សាសំណុំរឿងនេះជាមុន;

**កត់សម្គាល់ឃើញ**ថា ក្នុងអំឡុងពេលសវនាការលើបណ្តឹងសាទុក្ខ នួន ជា បានប្រកាសថា សហមេធាវីអន្តរជាតិរបស់គាត់ ពុំបានចូលរួមនៅក្នុងសវនាការនោះទេ និងបានណែនាំសហមេធាវីជាតិរបស់គាត់ "មិនឱ្យចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីទាំងនេះតទៅទៀត និងមិនឱ្យឆ្លើយតបទៅនឹងសំណួរណាមួយរបស់ចៅក្រម ឬភាគីដទៃទៀតឡើយ" តែទោះជាយ៉ាងណាក៏ដោយ"រក្សាបណ្តឹងសាទុក្ខរបស់[គាត់]វិញ"[6];

**កត់សម្គាល់ឃើញ**ថា នៅក្នុងសារណាជាលាយលក្ខណ៍អក្សរក្រោយមកទៀត សហមេធាវីជាតិការពារក្តី នួន ជា បានបញ្ជាក់ពីជំហរថា "នឹងទៅអង្គុយនៅក្នុងបន្ទប់សវនាការនៅពេលខាងមុខក្នុងសំណុំរឿង ០០២/០១" តែគាត់នឹងគោរពតាមការណែនាំរបស់កូនក្តីគាត់"មិនឱ្យឆ្លើយតបទៅនឹងសំណួររបស់ចៅក្រម ឬគ្រប់ភាគី"[7] និងថា សហមេធាវីអន្តរជាតិការពារក្តី នួន ជា បានអះអាងថា កូនក្តីរបស់គាត់"បានបញ្ជាក់

---

[5] អនុស្សរណៈស្តីពីការអនុវត្តន៍តាមទំព័រ ៣ ដល់ ៤។

[6] ប្រតិចារឹកចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឯកសារលេខ F1/4.1 ទំព័រ ១៤។

[7] ការឆ្លើយតបរបស់លោក សុន អរុណ ទៅនឹងសេចក្តីសម្រេចផ្ទាល់មាត់របស់អង្គជំនុំជម្រះតុលាការកំពូល ទាក់ទងនឹងព្រឹត្តិការណ៍នៅថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥, ការឆ្លើយតបនេះចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឯកសារលេខ F30/13 កថាខណ្ឌ ៩។

នៅពេលសវនាការថា នួន ជា បានណែនាំ[គាត់] មិនឱ្យមានវត្តមានក្នុងអំឡុងពេលសវនាការ” និងបាន លើកឡើងថា បើទោះបីជា អ.វ.ត.ក “តាមពិត និងតែងតែ ជាថ្នុកល្ខោនកប្លែង”ក៏ដោយ ក៏គាត់នឹងមិន លាលែងពីសហមេធាវីអន្តរជាតិការពារក្តី នួន ជា ឡើយ[8];

**ពិចារណាឃើញ**ថា បើទោះបីជា នួន ជា មានសិទ្ធិក្នុងការបោះបង់សិទ្ធិមិនធ្វើសារណាផ្ទាល់មាត់នៅ សវនាការបណ្តឹងសាទុក្ខក៏ដោយ ក៏ការសម្រេចចិត្តបែបនេះ នឹងប៉ះពាល់យ៉ាងខ្លាំងទៅលើលទ្ធភាពរបស់ គាត់ ក្នុងការលើកមធ្យោបាយការពារខ្លួនដោយប្រសិទ្ធភាព និងថា អាស្រ័យហេតុនេះ អង្គជំនុំជម្រះមាន ការជឿជាក់ថា តាមការឆ្លុះបញ្ចាំងនេះ នួន ជា នៅតែគោរពតាម និងយល់ដឹងយ៉ាងពេញលេញ និងទទួល យកផលវិបាកនៃការសម្រេចចិត្តបែបនេះ;

**ពិចារណាឃើញ**ថា នួន ជា នៅតែរក្សាសិទ្ធិក្នុងការដកវិញនូវការសម្រេចចិត្តរបស់ខ្លួនគ្រប់ពេល និងមាន សិទ្ធិចូលរួមយ៉ាងសកម្ម នៅក្នុងសវនាការលើបណ្តឹងសាទុក្ខតាមរយៈការធ្វើសារណាផ្ទាល់មាត់ និង/ឬ ការ ឆ្លើយតបទៅនឹងសំណួររបស់ចៅក្រមទាំងមូល ឬលើផ្នែកខ្លះ និងថា អាស្រ័យហេតុនេះ អង្គជំនុំជម្រះ នឹង ត្រូវផ្តល់ពេលវេលាទៅឱ្យក្រុមមេធាវីការពារក្តី នួន ជា នៅក្នុងកាលវិភាគសម្រាប់សវនាការលើបណ្តឹង សាទុក្ខ ប៉ុន្តែពេលវេលាដែលត្រូវបានផ្តល់នេះ នឹងត្រូវដកហូតវិញ ប្រសិនបើ នួន ជា នៅតែគោរពតាមការ សម្រេចចិត្តរបស់ខ្លួន ហើយសវនាការលើបណ្តឹងសាទុក្ខនឹងបន្តដំណើរការទៅតាមវគ្គនីមួយៗ ដូចដែលបាន កំណត់នៅក្នុងកាលវិភាគ;

## អាស្រ័យហេតុនេះសម្រេច÷

**បង្គាប់**ថា សវនាការលើបណ្តឹងសាទុក្ខ ត្រូវបន្តនៅថ្ងៃទី អង្គារ ទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៦ ម៉ោង ៩:00 ព្រឹក នៅក្នុងបន្ទប់សវនាការធំរបស់ អ.វ.ត.ក និងបន្តដល់ថ្ងៃ ពុធ ទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៦ និងថ្ងៃ ព្រហស្បតិ៍ ទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៦ និងថ្ងៃទី សុក្រ ទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ ដែលជាថ្ងៃបម្រុង;

**ភ្ជាប់ជាមួយ** នូវកាលវិភាគសម្រាប់សវនាការលើបណ្តឹងសាទុក្ខ[9];

---

[8] ការឆ្លើយតបរបស់ Victor KOPPE ទៅនឹងសំណើរបស់អង្គជំនុំជម្រះតុលាការកំពូលឱ្យពន្យល់ពីមូលហេតុដែលអវត្តមាន ពេលសវនាការបណ្តឹងសទុក្ខ, ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឯកសារលេខ F30/14/1 កថាខណ្ឌ ៨ និង ១០។

[9] ឧបសម្ព័ន្ធក – កាលវិភាគស្តាពរសម្រាប់សវនាការ ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារលេខ F30/17.1។

សំណុំរឿងលេខ: ០០២/១៩-កញ្ញា-២០០៧/អ.វ.ត.ក/អ.ជ.ត.ក

ឯកសារលេខ F30/17

**ណែនាំ**សហមេធាវីត្រៀមបម្រុងសម្រាប់ នួន ជា ត្រូវមានវត្តមាននៅក្នុងបន្ទប់សវនាការធំគ្រប់ពេលនៃសវនាការលើបណ្តឹងសាទុក្ខ និងត្រូវត្រៀមលក្ខណៈដើម្បីទទួលយកការការពារក្តីសម្រាប់ នួន ជា ភ្លាមៗ នៅពេលមានការបង្គាប់ពីអង្គជំនុំជម្រះនេះ;

**ស្នើ**ឱ្យសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ជូនដំណឹងមកក្រឡាបញ្ជីនៃអង្គជំនុំជម្រះតុលាការកំពូលតាមរយៈអ៊ីមែលយ៉ាងយូរត្រឹមថ្ងៃ សុក្រ ទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៦ ពីចំនួនដើមបណ្តឹងរដ្ឋប្បវេណីប្រសិនបើមាន ដែលត្រូវចូលអង្គុយនៅក្នុងបន្ទប់សវនាការធំនៅក្នុងអំឡុងពេលនៃសវនាការលើបណ្តឹងសាទុក្ខ;

**ជូនដំណឹង** នួន ជា ថា នៅពេលសវនាការលើបណ្តឹងសាទុក្ខបន្ត អង្គជំនុំជម្រះនឹងត្រូវសួរពីបញ្ហាថាតើគាត់ នៅតែគោរពតាមការសម្រេចចិត្តរបស់ខ្លួនមិនធ្វើសារណាផ្ទាល់មាត់ និងមិនឆ្លើយតបទៅនឹងសំណួររបស់ចៅក្រម និងថាតើ នួន ជា បានយល់ដឹងពេញលេញ និងទទួលយកផលវិបាកនៃការសម្រេចចិត្តបែបនេះដែរ ឬយ៉ាងណា។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១៥

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រីម**